**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ព្រះសីហនុ**

# នាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ព្រះសីហនុ

**សភាព្រហ្មទណ្ឌ**

**សំណុំរឿង**
លេខ: ២០១
ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២២

**សាលដីកា**
លេខ: ០១០/០២ ព្រទ ក្រ X
ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២៣

បង្កើតឡើងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស /រកម /០៧១៤ /០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់សាលាឧទ្ធរណ៍ មានដូចខាងក្រោម៖

**ជនជាប់ចោទ**

១. ឈ្មោះ [redacted] KUN ហៅ A ZHU ភេទ ប្រុស អាយុ ២២ឆ្នាំ ជនជាតិ ចិន មុខរបរ បុគ្គលិកហាងម៉ាស្សា កម្រិតវប្បធម៌ ថ្នាក់ទី៣ ។ កើតនៅខេត្ត [redacted] ប្រទេស ចិន មានទីលំនៅភូមិ [redacted] ខេត្ត ព្រះសីហនុ ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ជានីតិជនទោសពីមុន គ្មាន ។ ឃុំខ្លួន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៦ ត.ព(ជ)/២១ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្ត ព្រះសីហនុ ។ (ដើមបណ្តឹងឧទ្ធរណ៍)

ជាប់ចោទពីបទ ឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ។

២. ឈ្មោះ [redacted] XUAN YI ភេទ ប្រុស អាយុ ២៤ឆ្នាំ ជនជាតិ ចិន មុខរបរ អ្នកនាំ ភ្ញៀវចូលលេងកាស៊ីណូ កម្រិតវប្បធម៌ ថ្នាក់ទី៧ ។ កើតនៅខេត្ត [redacted] ប្រទេស ចិន មានទីលំនៅភូមិ [redacted] ខេត្ត ព្រះសីហនុ ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។ ឃុំខ្លួន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៧ ត.ព(ជ)/២១ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្ត ព្រះសីហនុ ។ (ដើមបណ្តឹងឧទ្ធរណ៍)

៣. ឈ្មោះ [redacted] KAI JIN ភេទ ប្រុស អាយុ ២២ឆ្នាំ ជនជាតិ ចិន មុខរបរ អ្នកនាំបុគ្គលិកធ្វើការអនឡាញ កម្រិតវប្បធម៌ ថ្នាក់ទី៧ ។ កើតនៅខេត្ត [redacted] ប្រទេស ចិន មានទីលំនៅភូមិ [redacted] ខេត្ត ព្រះសីហនុ ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ជានីតិជន



អាសយដ្ឋាន៖ ភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Address: Village3, Sangkat 1, Preah Sihanouk City, Preah Sihanouk Province.
ទូរស័ព្ទ៖ ០៩៨ ៨៨១ ៩២៦ / ០១២ ៦៤៥ ៦០៣
Phone: 098 881 926 / 012 645 603

ទោសពីមុន គ្មាន ។ ឃុំខ្លួន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៨ ត.ក(ជ)/២១ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្ត ព្រះសីហនុ ។ (ដើមបណ្តឹងឧទ្ធរណ៍)

ជាប់ចោទពីបទ សមគំនិតអំពើឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ។

៤. ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ភេទ ប្រុស អាយុ ៣៤ឆ្នាំ ជនជាតិ ចិន មុខរបរ គ្មាន កម្រិតវប្បធម៌ គ្មាន ។ កើតនៅខេត្ត [redacted] ប្រទេស ចិន មានទីលំនៅភូមិ [redacted] ខេត្ត ព្រះសីហនុ ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ជានីតិជន ទោសពីមុន គ្មាន ។ ឃុំខ្លួន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៩៩/២១ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្ត ព្រះសីហនុ ។ (ដើមបណ្តឹងឧទ្ធរណ៍)

ជាប់ចោទពីបទ ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ។

មានមេធាវី [redacted] ជាជា អត្តលេខ ២៣១២ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ។

មានអ្នកបកប្រែឈ្មោះ [redacted] គឹមហុង ភេទ ប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ ជាអ្នកបកប្រែភាសាចិន - ខ្មែរ អាសយដ្ឋានភូមិ ៤ សង្កាត់ លេខ៤ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ ។

**អង្គហេតុ**

កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ វេលាម៉ោង ០៨ និង០០ព្រឹក ស្ថិតនៅចំណុចតាមបណ្តោយផ្លូវសណ្ឋាគារឯករាជ្យ (សណ្ឋាគារប្រាំពីរជាន់) ស្ថិតនៅក្នុងភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ មានករណីជនសង្ស័យចំនួន ៣នាក់ រួមមាន ១.ឈ្មោះ [redacted] KUN ២.ឈ្មោះ [redacted] XUAN YI ៣.ឈ្មោះ [redacted] KAI JIN បានធ្វើសកម្មភាពដោយបើប្រាស់រថយន្តចំនួន ២ គ្រឿង ម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 និង ម៉ាក Ford Ranger ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AF-9376 ធ្វើសកម្មភាពបើកដេញតាមរថយន្ត ១ គ្រឿង ម៉ាក Range Rover ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2AL-9459 ដែលជារថយន្តរបស់ជនរងគ្រោះឈ្មោះ [redacted] XU ភេទ ប្រុស អាយុ ២៨ឆ្នាំ ជនជាតិ ចិន ។ លុះដល់ចំណុចកើតហេតុខាងលើជនល្មើសបានបើករថយន្តម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 2BI-1413 ខាងលើទៅអែបនឹងរថយន្តរបស់ជនរងគ្រោះរួចបានប្រើប្រាស់អាវុធខ្លី ០១ ដើម (មិនស្គាល់ម៉ាក) ធ្វើសកម្មភាពបាញ់ទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់ភ្លាមៗនៅក្នុងរថយន្តនៅនឹងកន្លែងកើតហេតុ រួចបានជិះយករថយន្តដែលប្រព្រឹត្តបទល្មើសទៅប្លុងចោលនៅលើដីឡូត៍មួយកន្លែងនៅម្តុំរង្វង់មូលតោ២ ។ សមត្ថកិច្ចជំនាញបានបន្តស្រាវជ្រាវ និងឆែកកាម៉េរ៉ាសុវត្ថិភាពតាមផ្លូវចាប់តាំងពីចំណុចដែលជនសង្ស័យយករថយន្តម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 2BI-1413 ទៅប្លុងចោលដោយនៅទីនោះ មានជនសង្ស័យចំនួន ៣នាក់ សុទ្ធតែពាក់អាវពណ៌ខ្មៅបានចុះពីរថយន្ត ទើបសមត្ថកិច្ចជំនាញបន្តឆែកកាមេរ៉ាសុវត្ថិភាពតាមផ្លូវរហូតដល់ចំណុចហាងបាយមុខសណ្ឋាគារ លីងហាង ហើយកម្លាំងសមត្ថកិច្ចក៏បានធ្វើការឆែកឆេរនៅសណ្ឋាគារ លីងហាង បន្ទប់លេខ ៨៥១២ ហើយធ្វើការឃាត់ខ្លួនបានជនសង្ស័យម្នាក់ទៀតឈ្មោះ [redacted] KUN ។ សមត្ថកិច្ចបន្តធ្វើការឆែកកាមេរ៉ាសុវត្ថិភាពឃើញថាមានជនសង្ស័យចំនួន ២នាក់ទៀត បានចេញពីបន្ទប់លេខ ៨៥១២ នៃសណ្ឋាគារ លីងហាង ដើរទៅស្នាក់នៅសណ្ឋាគារដែលនៅក្បែរនោះ ទើបកម្លាំងសមត្ថកិច្ចបន្តធ្វើការឆែកឆេរនៅសណ្ឋាគារមួយទៀតដែលនៅកែងផ្លូវចំការស្តៅហើយបានធ្វើការឃាត់ខ្លួន [redacted] XUAN YI ចំណែកជនសង្ស័យម្នាក់ទៀត ព្រមទាំងបក្ខពួកកម្លាំងសមត្ថកិច្ចជំនាញ



Scanned with CamScanner

175/3

កំពុងស្វែងរកឃាត់ខ្លួន ។ ចំពោះរថយន្ត ០២គ្រឿង ១/ម៉ាក Ford Raptors ពណ៌ ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 ជាមធ្យោបាយជិះប្រព្រឹត្តបទល្មើស និងមានសំបកកាទុស ០៤ គ្រាប់ បន្សល់ទុកនៅលើកៅអីមុខផ្នែកខាងស្តាំក្នុងរថយន្តនេះ ២/ម៉ាក Ford Ranger ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AF-9376 ជាមធ្យោបាយជិះប្រព្រឹត្តបទល្មើសជិះបិទផ្លូវ និងវត្ថុតាងផ្សេងទៀតត្រូវបានសមត្ថកិច្ចដកហូតជាបណ្តោះអាសន្ន ។ តាមការពិនិត្យកន្លែងកើតហេតុលទ្ធផលកោសលវិច័យលើស្លាកស្នាមសាកសព និងរថយន្តទាំង ២គ្រឿង ហើយជនសង្ស័យអង្គុយនៅកៅអីខាងមុខចំហៀងខាងស្តាំជាកន្លែងដែលខ្ទាំងកាំភ្លើងបាញ់ចេញមកថែមទាំងសំបកកាទុសបានធ្លាក់នៅលើកៅអីដែលជនសង្ស័យអង្គុយទៀត ដែលនេះបង្ហាញឱ្យឃើញថាជនសង្ស័យឈ្មោះ [redacted] KUN ជាអ្នកបាញ់សម្លាប់ជនរងគ្រោះពិតមែនប៉ុន្តែជនសង្ស័យរឹងរូសមិនព្រមសារភាពដោយម្តងឆ្លើយថាអ្នកបើករថយន្តជាអ្នកបាញ់ ហើយម្តងទៀតថាអ្នកដែលជិះពីក្រោយជាអ្នកបាញ់ទៅវិញ ។ ក្រោយការសាកសួរឃើញថា មានពាក់ព័ន្ធនឹងជនសង្ស័យឈ្មោះ [redacted] GE ឈ្មោះ [redacted] SHAO HONG ហៅ [redacted] ZI ឈ្មោះ [redacted] LIAN QI និងឈ្មោះ [redacted] DONG ជាមេក្លោង និងជាអ្នករៀបចំផែនការបាញ់សម្លាប់នោះ ចំណែកជនសង្ស័យឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN ជាបានសហការសមគំនិតគ្នាប្រព្រឹត្តករណីខាងលើនេះ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១៣/០៧ ក្រ.៣ (ឈ) ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្ត ព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចខាងក្រោម ៖

១-ឱ្យឈ្មោះ [redacted] KUN ហៅ A ZHU ភេទ ប្រុស អាយុ ២២ឆ្នាំ ជនជាតិ ចិន (មានសាវតារជាតិដូចខាងលើ) រួចផុតបទចោទពីបទ កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោសលើៈ

២.១ ឈ្មោះ [redacted] KUN ហៅ A ZHU ភេទ ប្រុស អាយុ ២២ឆ្នាំ ជនជាតិ ចិន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ (ដប់ប្រាំបី) ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

២.២ ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ភេទ ប្រុស អាយុ ៣៤ឆ្នាំ ជនជាតិ ចិន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ (ដប់ប្រាំបី)ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

២.៣ ឈ្មោះ [redacted] XUAN YI ភេទ ប្រុស អាយុ ២៤ឆ្នាំ ជនជាតិ ចិន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ និងឈ្មោះ [redacted] KAI JIN ភេទ ប្រុស អាយុ ២៣ឆ្នាំ ជនជាតិ ចិន (មានសាវតារជាតិដូចខាងលើ) ដាក់ដាក់ពន្ធនាគារម្នាក់កំណត់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ ពីបទ សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

៣-ហាមឃាត់ដល់ឈ្មោះ [redacted] KUN ហៅ A ZHU ភេទ ប្រុស អាយុ ២២ឆ្នាំ ជនជាតិ ចិន (មានសាវតារជាតិដូចខាងលើ) ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ភេទ ប្រុស អាយុ ៣៤ឆ្នាំ ជនជាតិ ចិន (មានសាវតាជាតិដូចខាងលើ) ឈ្មោះ [redacted] XUAN YI ភេទ ប្រុស អាយុ ២៤ឆ្នាំ ជនជាតិ ចិន (មានសាវតារជាតិដូចខាងលើ) និងឈ្មោះ [redacted] KAI JIN ភេទ ប្រុស អាយុ ២៣ឆ្នាំ ជនជាតិ ចិន ( មានសាវតារជាតិដូចខាងលើ) ស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជារយៈពេល ០៥ (ប្រាំ)ឆ្នាំ បន្ទាប់ពីអនុវត្តទោសក្នុងពន្ធនាគារចប់ជាស្ថាពរ តាមបញ្ញត្តិមាត្រា ២០៦ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៤-រឹបអូសវត្ថុតាងរួមមាន ៖ ទូរស័ព្ទ ០៧គ្រឿង (ម៉ាក VIVO ពណ៌ខ្មៅ ចំនួន ០២គ្រឿង IPHONE 6 ចំនួន ០២គ្រឿង ម៉ាក VIVO ពណ៌ទឹកមាស ចំនួន ០១គ្រឿង ម៉ាក REDMI ចំនួន ០១គ្រឿង និងម៉ាក អូប៉ូ ចំនួន ០១គ្រឿង តាមបញ្ញត្តិមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

៥-ប្រគល់ឱ្យម្ចាស់ដើមវិញនូវ ៖ លិខិតឆ្លងដែនចំនួន ០២ក្បាល (ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KUN) តាមបញ្ញត្តិមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ HUANG KUN ឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ។

ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ២៣៧ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់មេធាវី ទន់ គីមហួយ (ការពារសិទ្ធិឱ្យឈ្មោះ [redacted] KUN ឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG) ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៣/០៧ ក្រ៣ (ឈ) ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្ត ព្រះសីហនុ ត្រង់ចំណុចផ្ដន្ទាទោស នៃសេចក្ដីសម្រេច ។

បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ព្រះសីហនុ ។

បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ។

**នាពេលសវនាការ**

- ក្រោយពីបាន ស្ដាប់អំណានរបាយការណ៍រឿង ។

- ក្រោយពីបាន ស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ឆ្លើយថា: ខ្លួនជាអ្នកបាញ់សម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU ព្រោះខ្លួនខឹងឈ្មោះ [redacted] XU ពេលចាប់ជម្រិតខ្លួនគាត់បានវាយធ្វើបាបខ្លួន និងបានលក់ខ្លួនទៅឱ្យក្រុមហ៊ុនអនឡាញផ្សេង ហើយទារលុយពីឪពុកម្ដាយខ្លួននៅប្រទេសចិន អស់លុយជិត ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក ក្រោយមកខ្លួនបានរត់គេចខ្លួនរួចផុតពីការធ្វើបាបរបស់ពួកគេ ។ នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២១ ពួកខ្លួនមានគ្នា ០៣នាក់ ឈ្មោះ [redacted] LIAN QI និងឈ្មោះ [redacted] ZI បានជិះរថយន្ត១គ្រឿង ម៉ាក Ford Raptor ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 មកចូល KTV ជាន់ទី ៦ មកច្រៀងរាំលេង លុះពេលភ្លឺស្រាងៗឈានចូលថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ពួកខ្លួនចេញពី KTV ចៃដន្យបានជួបជនរងគ្រោះឈ្មោះ [redacted] XU នៅមុខវត្តលើ ខ្លួនបានចុះពីឡានគាស់កញ្ចក់ឡាន តែជនរងគ្រោះមិនឆ្លើយតប ខ្លួនបានឱ្យឈ្មោះ [redacted] LIAN QI ជាអ្នកបើកឡានតាមពីក្រោយ លុះទៅដល់បណ្ដោយផ្លូវសណ្ឋាគារឯករាជ្យ (សណ្ឋាគារប្រាំពីរជាន់) ស្ថិតនៅក្នុងភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ ខ្លួនបានបាញ់សម្លាប់ទៅជនរងគ្រោះតែម្ដង បន្ទាប់មកបានបើករថយន្តទៅចតទុកចោលនៅចំណុចដីឡូត៍មួយកន្លែងនៅម្ដុំតោ២ ហើយពួកខ្លួនចែកផ្លូវគ្នាដោយខ្លួនជិះ Pass App ម្នាក់ឯងទៅដេកនៅសណ្ឋាគារ លីងហា បន្ទប់លេខ ៨៥១២ ចំណែកឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ [redacted] DONG ពួកគេនេះមិនបានចូលរួមធ្វើសកម្មភាពសម្លាប់ជនរងគ្រោះនោះទេ ។

- ក្រោយពីបាន ស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ [redacted] DONG ឆ្លើយថា: ខ្លួនមិនបានចូលរួមសម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU នោះទេ ខ្លួនមិនស្គាល់ឈ្មោះ [redacted] KUN ហៅ A ZHU នោះទេ ហើយក៏ខ្លួនមិនស្គាល់ជនរងគ្រោះឈ្មោះ [redacted] XU ដែរ ខ្លួនមិនបាននៅទីតាំងកើតហេតុ

នោះទេ សមត្ថកិច្ចឃាត់ខ្លួននៅផ្លូវជាតិលេខ ៤ ជិតព្រលានយន្តហោះ កងកេង ករណីគ្រឿងញៀន ដោយសារខ្លួនបានទិញគ្រឿងញៀនយកមកប្រើប្រាស់ជាមួយសង្សាររបស់ខ្លួន មិនបានជួញដូរ និងលក់គ្រឿងញៀនបន្តទេ ហេតុអ្វីបានជាតុលាការផ្តន្ទាទោស ១៨ (ដប់ប្រាំបី)ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ព្រោះខ្លួនមិនបានប្រព្រឹត្តនោះទេ ។ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ខ្លួននៅ KTV ៩ នៅជាន់ទី៤ ហើយខ្លួនមកទីនេះម៉ោងប្រហែល ៣ ឬ៤ ទៀបភ្លឺបានជួបមិត្តភក្តិជាច្រើន ក្រោយមកម៉ោងប្រហែល ៧ ព្រឹក ខ្លួនបានជិះ Pass App ទៅលេងហ្គេមបាញ់ត្រីនៅជំរំ ៥ ដោយសារមិត្តភក្តិខ្លួននៅទីនោះហៅខ្លួនទៅលេងជាមួយពួកគេ ។ ខ្លួនបានលេងហ្គេមបាញ់ត្រីនៅទីនោះ រហូតដល់ពេលរសៀល ទើបឃើញសារព័ត៌មានចិនចេញផ្សាយថា មានករណីបាញ់គ្នាសម្លាប់ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted]XUAN YI និងឈ្មោះ [redacted]KAI JIN នោះទេ ។

- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] XUAN YI ឆ្លើយថា: ខ្លួនស្គាល់ឈ្មោះ [redacted]KUN ហៅ A ZHU ព្រោះពីមុនមកធ្លាប់ធ្វើការងារជាមួយគ្នា នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២១ ខ្លួននៅកន្លែងស្នាក់នៅរបស់ខ្លួនស្ថិតនៅសណ្ឋាគារ ហ៊ីលិ ខ្លួនមិនបានចេញទៅណានោះទេ មានកាមេរ៉ាសុវត្ថិភាពអាចបញ្ជាក់ភស្តុតាង ។ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ម៉ោងប្រហែលជា ៧ ព្រឹក ខ្លួនបានមកហូបអាហារពេលព្រឹកនៅមុខកន្លែងស្នាក់របស់ឈ្មោះ [redacted] KUN ហៅ A ZHU ចៃដន្យបានជួបឈ្មោះ [redacted] KUN ហៅ A ZHU ពេលហូបអាហាររួចហើយបានជជែកជាមួយ [redacted] KUN ហៅ A ZHU រួចបានឡើងលេងបន្ទប់ [redacted] KUN ហៅ A ZHU បានប្រហែល១០ នាទី ហើយខ្លួនក៏បានត្រឡប់ទៅកន្លែងស្នាក់នៅវិញ ។ ខ្លួនមិនបានប្រព្រឹត្តពីបទ សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន នោះទេ ក្នុងពេលដែលខ្លួនឡើងទៅលេងបន្ទប់ឈ្មោះ [redacted] KUN ហៅ A ZHU ក៏មិនបានពូនិយាយអ្វីនោះដែរ ខ្លួនមិនស្គាល់ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted]FAN CONG ហៅ XIAO DONG នោះទេ ។

- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]KAI JIN ឆ្លើយថា: នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ខ្លួនមិនបានចេញទៅណានោះទេ គឺស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួន មានកាម៉េរ៉ាសុវត្ថិភាពជាភស្តុតាង ប៉ុន្តែខ្លួនស្គាល់ឈ្មោះ [redacted]KUN ហៅ A ZHU បានប្រហែលជា ១០ថ្ងៃ មិនជិតស្និតទេ ចំណែកឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted]FAN CONG ហៅ XIAO DONG ខ្លួនមិនស្គាល់ទេ ខ្លួនគ្មានរថយន្តទេ ម្ចាស់រថយន្តម៉ាក Ford Raptor ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 គឺឈ្មោះ [redacted]LIAN QI ជាអ្នកជួលគេមិនដឹងតម្លៃប៉ុន្មាននោះទេក្នុងមួយខែ ខ្លួនស្នាក់នៅជិតបន្ទប់របស់ឈ្មោះ [redacted]LIAN QI ខ្លួនមិនបានស្ថិតនៅក្នុងហេតុការណ៍នោះទេ ហើយខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះឡើយ ។

- ក្រោយពីបាន ស្តាប់តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ នៅក្នុងសំណុំរឿងនេះជនជាប់ចោទមានចំនួន ០៤ នាក់ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU បានសារភាពថា ខ្លួនជាអ្នកបាញ់សម្លាប់ជនរងគ្រោះឈ្មោះ PENG XU ដោយសារជនរងគ្រោះចាប់ជម្រិតខ្លួន បានវាយធ្វើបាប ហើយទារលុយពីឪពុកម្តាយខ្លួននៅប្រទេសចិនអស់លុយជិត ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក ក្រោយមកខ្លួនបានរត់គេចខ្លួនពីការធ្វើបាបពីឈ្មោះ [redacted] XU ហើយការផ្តន្ទាទោសរបស់សាលាដំបូងខេត្តព្រះសីហនុ ធុនល្មមទៅនឹងការប្រព្រឹត្តបទល្មើស ចំណែកជនជាប់ចោទឈ្មោះ [redacted]XUAN YI , ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG មិនបានចូលរួមធ្វើសកម្មភាពសម្លាប់ជនគ្រោះនោះទេ ដូចនេះ តំណាងមហាអយ្យការ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងពិចារណាតាមច្បាប់ ។

- ក្រោយពីបាន ស្តាប់មេធាវី [redacted] ជាជា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU បានសារភាពថា ខ្លួនជាអ្នកបាញ់សម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU ចំណែកជនជាប់ចោទឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted]FAN CONG ហៅ XIAO DONG មិនបានចូលរួមធ្វើសកម្មភាពសម្លាប់ជនគ្រោះនោះទេ ។ ជនជាប់ចោទឈ្មោះ [redacted] XUAN YI បានបញ្ជាក់ថា នៅថ្ងៃកើតហេតុ



Scanned with CamScanner

ខ្លួនមិនបានចេញទៅណានោះទេ ហើយមានការម៉េរ៉ាសុវត្ថិភាពជាភស្តុតាង ចំណែកជនជាប់ចោទឈ្មោះ [redacted] KAI JIN បានបញ្ជាក់ដែរថា គឺស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួន មានការម៉េរ៉ាសុវត្ថិភាពជាភស្តុតាងនៅក្នុងបន្ទប់ជាមួយមិត្តស្រីរបស់ខ្លួន រីឯជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ [redacted] DONG ក៏បានបញ្ជាក់ផងដែរថា នៅពេលកើតហេតុខ្លួនមិនបាននៅទីតាំងកើតហេតុនោះទេ ហើយក៏មិនស្គាល់ឈ្មោះ [redacted] KUN ហៅ A ZHU ដែលជាជនដៃដល់នេះដែរ សមត្ថកិច្ចឃាត់ខ្លួននៅផ្លូវជាតិលេខ ៤ ជិតព្រលានយន្តហោះ កងកេង ករណីគ្រឿងញៀន នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ម៉ោងប្រហែល ០៦ និង ៣០នាទី ទៅម៉ោង ០៧ ព្រឹក ខ្លួននៅជំរំ ៥ លេងហ្គេមបាញ់ត្រីនៅទីនោះ ។ ដូចនេះ គ្មានភស្តុតាងណាមួយបញ្ជាក់ថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] FAN CONG ហៅ XIAO DONG បានប្រព្រឹត្តបទ ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិ ១ សង្កាត់លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ នោះឡើយ ហើយក៏គ្មានភស្តុតាងបញ្ជាក់ថា កូនក្តីខ្លួនឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN បានប្រព្រឹត្តបទ សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិ ១ សង្កាត់លេខ៣ ក្រុង ព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា ២៩ និង មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនោះដែរ ។ ដូចនេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ សម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ និងដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពឡើងវិញ ។

- ក្រោយពីបាន ស្តាប់អំណានរបាយការណ៍ ឯកសារ និង កំណត់ហេតុផ្សេងៗទៀត ។
- ក្រោយពីបាន ពិនិត្យភស្តុតាងពាក់ព័ន្ធ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាឧទ្ធរណ៍ យល់ឃើញថា

១- បណ្តឹងឧទ្ធរណ៍លេខ ២៣៧ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់មេធាវី ទន់ គឹមហួយ ការពារសិទ្ធិឱ្យឈ្មោះ [redacted] KUN ហៅ A ZHU ឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៣/០៧ ក្រ.៣ (ឈ) ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្ត ព្រះសីហនុ ត្រង់ចំណុចផ្តន្ទាទោស នៃសេចក្តីសម្រេច ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ព្រះសីហនុទទួលជំនុំជម្រះជាសមត្ថកិច្ច យោងតាមបញ្ញត្តិមាត្រា ៣៧៣ មាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- ជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU បានសារភាពថា ខ្លួនជាអ្នកបាញ់សម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU ព្រោះខ្លួនខឹងជនរងគ្រោះចាប់ជម្រិតខ្លួនបានវាយធ្វើបាប និងបានលក់ទៅឱ្យក្រុមហ៊ុនអនឡាញផ្សេង ។ នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២១ ពួកខ្លួនមានគ្នា ០៣នាក់ ឈ្មោះ [redacted] LIAN QI និងឈ្មោះ PANG ZI បានជិះរថយន្ត១គ្រឿង ម៉ាក Ford Raptor ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 ដោយក្នុងរថយន្តមានកាំភ្លើងមួយដើមជារបស់ឈ្មោះ [redacted] LIAN QI ដែលជាអ្នកបើករថយន្តខ្លួនអង្គុយនៅខាងមុខដោយមិនមានឈ្មោះ [redacted] FAN CONG ហៅ [redacted] DONG ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN ជិះរថយន្តជាមួយ និងចូលរួមសកម្មភាពសម្លាប់ជនរងគ្រោះនោះទេ ។ ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបញ្ជាក់ថា ឈ្មោះ [redacted] KUN ហៅ A ZHU ជាអ្នកសម្លាប់ជនរងគ្រោះដោយមានសំបកកាទុសនៅក្រោមកៅអីខាងស្តាំជាប់អ្នកបើករថយន្ត ហើយសាក្សីឈ្មោះ ប៊ុន ម៉េងហុង ជាអ្នកបើករថយន្តឱ្យជនរងគ្រោះ ក៏បានបញ្ជាក់ដែរថា នៅថ្ងៃកើតហេតុនោះ គឺមានរថយន្ត១គ្រឿង ម៉ាក Ford Raptor ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 បានជិះតាមរថយន្តរបស់ខ្លួន និងបានបាញ់មកលើរថយន្តរបស់ខ្លួនបណ្តាលឱ្យត្រូវជនរងគ្រោះតែម្តង ។

៣- ជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ XIAO DONG បានឆ្លើយបដិសេធថា ខ្លួនមិនបានចូលរួមសម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU នោះទេ ខ្លួនមិនស្គាល់ឈ្មោះ [redacted] KUN ហៅ A ZHU នោះទេ

ហើយក៏មិនស្គាល់ជនរងគ្រោះឈ្មោះ [redacted] XU ដែរ ។ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ម៉ោងប្រហែល ៧ ព្រឹក ខ្លួនបានជិះ PASS APP ទៅលេងហ្គេមបាញ់ត្រីនៅជំរី ៥ សមត្ថកិច្ចឃាត់ខ្លួននៅផ្លូវជាតិលេខ ៤ ជិតព្រលានយន្តហោះ កងកេង ករណីគ្រឿងញៀនដោយសារខ្លួនបានទិញគ្រឿងញៀនយកមកប្រើប្រាស់ជាមួយសង្សារមិនបានជួញដូរ និងលក់គ្រឿងញៀនបន្តទេ ។ ពេល្មោះ យ៉េង យ៉ុង ជាសាក្សីក៏បានបញ្ជាក់ថា បានឃើញឈ្មោះ [redacted] FAN CONG ហៅ XIAO DONG លេងហ្គេមបាញ់ត្រីនៅជំរី ៥ ម៉ោងប្រហែល ៧ ព្រឹក ដែរ ហើយក៏គ្មានសាក្សីណាមួយឃើញឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ចូលរួមសម្លាប់ជនរងគ្រោះនោះដែរ ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ក៏ស្របជាមួយចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ដែលថាមិនមានឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ចូលរួមសម្លាប់ជនរងគ្រោះនោះ ទេ ។

៤- ជនជាប់ចោទឈ្មោះ [redacted] XUAN YI បានឆ្លើយបដិសេធថា ខ្លួនមិនបានចូលរួមសម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU នោះទេ នៅថ្ងៃកើតហេតុខ្លួនកំពុងស្នាក់នៅបន្ទប់នៃសណ្ឋាគារ ហ៊ីលិ ជាមួយសង្សាររបស់ខ្លួនជនជាតិចិន មិនបានទៅណាឡើយ ។ ម៉ោងប្រហែល ៧ ព្រឹក ខ្លួនបានមកហូបអាហារពេលព្រឹក បានជួបឈ្មោះ HUANG KUN ហៅ A ZHU ពេលហូបអាហាររួចហើយបានជជែកជាមួយ [redacted] KUN ហៅ A ZHU រួចបានឡើងលេងបន្ទប់ [redacted] KUN ហៅ A ZHU បានប្រហែល ១០ នាទី ហើយខ្លួនក៏បានត្រឡប់ទៅកន្លែងស្នាក់នៅវិញ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG នោះទេ ខ្លួនមានកាមេរ៉ាសុវត្ថិភាពអាចបញ្ជាក់បានថា ខ្លួនមិនបានចេញទៅណានោះទេ ចំណុចនេះបែរជាមន្ត្រីនគរបាលយុត្តិធម៌ពុំបានបង្ហាញភស្តុតាងជាកាមេរ៉ាសុវត្ថិភាពមកបញ្ជាក់ឱ្យច្បាស់នោះទេ ហើយជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] XUAN YI មិនបានចូលរួមសម្លាប់ជនរងគ្រោះនោះដែរ ។

៥- ជនជាប់ចោទឈ្មោះ [redacted] KAI JIN បានឆ្លើយថា នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ខ្លួនមិនបានចេញទៅណានោះទេ គឺស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួន មានកាម៉េរ៉ាសុវត្ថិភាពជាភស្តុតាងបញ្ជាក់ ខ្លួនគ្មានរថយន្តទេ រថយន្តម៉ាក Ford Raptor ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 គឺជារបស់ឈ្មោះ [redacted] LIAN QI ។ ខ្លួនស្នាក់នៅជិតបន្ទប់របស់ឈ្មោះ [redacted] LIAN QI ចំណែកឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ខ្លួនមិនស្គាល់ទេ ។ ពាក់ព័ន្ធចំនុចនេះជាមន្ត្រីនគរបាលយុត្តិធម៌ ក៏ពុំបានបង្ហាញភស្តុតាងជាកាមេរ៉ាសុវត្ថិភាពបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] KAI JIN ពិតជានៅ ឬមិនៅកន្លែងស្នាក់នៅនោះដែរ លើសពីនេះឈ្មោះ HUANG KUN ហៅ A ZHU បានបញ្ជាក់ដែរថាជនជាប់ចោទឈ្មោះ [redacted] KAI JIN មិនបានចូលរួមសម្លាប់ជនរងគ្រោះនោះទេ ។

៦- យោងតាមចំណុច ២, ៣, ៤ និងចំណុច ៥ នៃសំអាងហេតុខាងលើ ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ពិតជាបានសម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU ដោយជិះរថយន្តម៉ាក Ford Raptor ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2BI-1413 ជាមួយឈ្មោះ [redacted] LIAN QI និងឈ្មោះ PANG ZI ពិតមែន ។ ដោយឡែកឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ពុំមានភស្តុតាងថាបានចូលរួមសម្លាប់ជនរងគ្រោះនោះទេ ហើយក៏មានភស្តុតាងមួយចំនួនបញ្ជាក់បានថាឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG មិនបានចូលរួមប្រព្រឹត្តបទល្មើសជាមួយឈ្មោះ [redacted] KUN ហៅ A ZHU នោះដែរ ។ ជាមួយគ្នានេះតុលាការកត់សម្គាល់ឃើញថា មានវិមតិសង្ស័យជាច្រើនដែលពុំកំណត់បានថាឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ជាអ្នកចូលរួមសម្លាប់ជនរងគ្រោះ ដូចបានបញ្ជាក់ក្នុងសំអាងហេតុខាងលើ ដែលចំណុចនេះ គប្បីបានជាប្រយោជន៍ដល់ជនជាប់ចោទ យោងតាមបញ្ញត្តិមាត្រា ៣៨ រដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

៧- តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU បានសារភាពថា ខ្លួនជាអ្នកបាញ់សម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU ដោយសារជនរងគ្រោះចាប់ជម្រិតខ្លួន វាយធ្វើបាប ហើយទារលុយពីឪពុកម្ដាយខ្លួននៅប្រទេសចិន អស់លុយជិត ៣០០០០ (បីម៉ឺន ) ដុល្លារអាមេរិក ក្រោយមកខ្លួនបានរត់គេចពីការធ្វើបាបពីឈ្មោះ [redacted] XU ហើយការផ្ដន្ទាទោសរបស់សាលាដំបូងខេត្ត ព្រះសីហនុ ធុនល្មមទៅនឹងការប្រព្រឹត្តបទល្មើស ចំណែកជនជាប់ចោទឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG មិនបានចូលរួមធ្វើសកម្មភាពសម្លាប់ជនរងគ្រោះនោះទេ ។ ដូចនេះ តំណាងមហាអយ្យការ សុំឱ្យក្រុមប្រឹក្សា ពិនិត្យ និងពិចារណាតាមច្បាប់ ។ សភាព្រហ្មទណ្ឌយល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ មានលក្ខណៈសមស្រប គប្បីសភាព្រហ្មទណ្ឌពិចារណា ដូចដែលបានលើកឡើងក្នុងសំអាងហេតុនេះ ។

៨- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនឈ្មោះ [redacted] KUN ហៅ A ZHU បានសារភាពថា ខ្លួនជាអ្នកបាញ់សម្លាប់ជនរងគ្រោះឈ្មោះ [redacted] XU ចំណែកជនជាប់ចោទឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG មិនបានចូលរួមធ្វើសកម្មភាពសម្លាប់ជនគ្រោះនោះទេ ។ ជនជាប់ចោទឈ្មោះ [redacted] XUAN YI បានបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនមិនបានចេញទៅណានោះទេ ហើយមានកាម៉េរ៉ាសុវត្ថិភាពជាភស្តុតាង ចំណែកជនជាប់ចោទឈ្មោះ [redacted] KAI JIN បានបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួន គឺស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួនមានកាម៉េរ៉ាសុវត្ថិភាពជាភស្តុតាងនៅក្នុងបន្ទប់ជាមួយមិត្តស្រីរបស់ខ្លួន រីឯជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ក៏បានបញ្ជាក់ផងដែរថា នៅពេលកើតហេតុខ្លួនមិនបាននៅទីតាំងកើតហេតុនោះទេ ហើយក៏មិនស្គាល់ឈ្មោះ [redacted] KUN ហៅ A ZHU ដែលជាជនដៃដល់នេះដែរ កូនក្ដីខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួននៅផ្លូវជាតិលេខ ៤ ជិតព្រលានយន្តហោះកងកេង ករណីគ្រឿងញៀន នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ម៉ោងប្រហែល ០៦ និង ៣០នាទី ទៅម៉ោង ០៧ ព្រឹក កូនក្ដីខ្លួននៅជំរឺ ៥ លេងហ្គេមបាញ់ត្រីនៅទីនោះ ។ ដូចនេះ គ្មានភស្តុតាងណាមួយបញ្ជាក់ថា កូនក្ដីខ្លួនឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ប្រព្រឹត្តបទ ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ នោះឡើយ ហើយក៏គ្មានភស្តុតាងបញ្ជាក់ថា កូនក្ដីខ្លួនឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN ប្រព្រឹត្តបទ សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ នោះដែរ ។ សភាព្រហ្មទណ្ឌ យល់ឃើញថា សេចក្ដីសន្និដ្ឋានការពាររបស់មេធាវី គប្បីសភាព្រហ្មទណ្ឌពិចារណា ដូចដែលបានលើកឡើងក្នុងសំអាងហេតុនេះ ។

៩- មានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់កំណត់បានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ពីបទ **ឃាតកម្មគិតទុកជាមុន** តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។ ពុំមានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់ កំណត់បានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ពីបទ **ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ និងជនជាប់ចោទឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN ពីបទ **សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន** តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។ អង្គហេតុប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ។

១០- យោងលើលទ្ធផលនាពេលសវនាការនេះ ឃើញថា រឿងក្ដីនេះផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ ត្រូវបានសាលាដំបូងខេត្ត ព្រះសីហនុ លើកយកសំអាងហេតុមកបញ្ជាក់ និងសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវខ្លះ ដែលត្រូវរក្សាទុកនៅដដែល លើកលែងតែសំអាងហេតុ និងសេចក្ដីសម្រេចត្រង់ចំណុច ២ និងចំណុច ៣ លើឈ្មោះ [redacted] KUN ហៅ A ZHU ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ឈ្មោះ [redacted]



Scanned with CamScanner

XUAN YI និងឈ្មោះ [redacted] KAI JIN ត្រូវកែប្រែដោយសម្រេចជាថ្មី ។ ដោយនៅក្នុងរឿងក្តីនេះ មានបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ គប្បីពិចារណាបន្ថយការផ្តន្ទាទោសនូវទោសដាក់ពន្ធនាគារមួយផ្នែកដល់ជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ក្នុងន័យអនុគ្រោះដល់ជនជាប់ចោទរូបនេះ ស្របតាមបញ្ញត្តិមាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ មួយវិញទៀត ចំពោះឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN ដែលពុំមានពិរុទ្ធភាពចំពោះបទចោទប្រកាន់ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍សម្រេចឱ្យរួចខ្លួនពីបទចោទ និងការប្រកាសទោសបន្ថែមដែលហាមឃាត់ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាលើជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN ។

១១-សាលក្រមព្រហ្មទណ្ឌលេខ ១១៣/០៧ ក្រ.៣ (ឈ) ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្ត ព្រះសីហនុ សម្រេចត្រឹមត្រូវតាមច្បាប់ហើយ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ តម្កល់ទុកជាបានការ លើកលែងតែចំណុច ២ និង ៣ នៃសេចក្តីសម្រេច ត្រូវកែប្រែ ដូចការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ **មិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៣៧ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់មេធាវី [redacted] គីមហួយ (ការពារសិទ្ធិឱ្យឈ្មោះ [redacted] KUN ហៅ A ZHU ឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៣/០៧ ក្រ.៣ (ឈ) ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្ត ព្រះសីហនុ ទុកជាបានការ លើកលែងតែចំណុចការផ្តន្ទាទោសដាក់ពន្ធនាគារ និងការប្រកាសទោសបន្ថែមដែលហាមឃាត់ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាលើជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN (ចំណុចទី ២ និង ៣) ត្រូវកែប្រែមកសម្រេចជាថ្មី ដូចខាងក្រោម:

២.១. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១៦(ដប់ប្រាំមួយ)ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

២.២. ឱ្យឈ្មោះ [redacted] FAN CONG ហៅ XIAO DONG (មានសាវតារជាតិដូចខាងលើ) រួចខ្លួនពីបទ ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ និងឱ្យឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN (មានសាវតារជាតិដូចខាងលើ) រួចខ្លួនពីបទ សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា ២៩ មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

អង្គហេតុប្រព្រឹត្តនៅភូមិ ១ សង្កាត់ លេខ៣ ក្រុង ព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ ។

២.៣. បង្គាប់ឱ្យដោះលែងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN (មានសាវតារជាតិដូចខាងលើ) ចេញពីពន្ធនាគារជាបន្ទាន់ ប្រសិនបើឈ្មោះនេះ មិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

២.៤. ហាមឃាត់ឈ្មោះ [redacted] KUN ហៅ A ZHU (មានសាវតារជាតិដូចខាងលើ) ស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជារយៈពេល ០៥ (ប្រាំ)ឆ្នាំ បន្ទាប់ពីអនុវត្តទោសក្នុងពន្ធនាគារចប់ជាស្ថាពរ តាមបញ្ញត្តិមាត្រា ២០៦ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៣- សាលដីកានេះ ជំនុំជម្រះ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] KUN ហៅ A ZHU ឈ្មោះ [redacted] XUAN YI ឈ្មោះ [redacted] KAI JIN និងឈ្មោះ [redacted] FAN CONG ហៅ XIAO DONG និងប្រកាសនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២៣ ។ ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| [redacted] | [redacted] [redacted] | [redacted] |



Scanned with CamScanner